# ការកំណត់ចំនួន

## ក្រោហ្វិចឱ្យសិស្សជ្រើសរើសវិធីផ្សេងៗ

សុំឱ្យកូនរបស់អ្នកជ្រើសរើសសកម្មភាពមួយឬច្រើនដែលបានបង្ហាញខាងក្រោម។ ការជ្រើសរើសនិងការបន្តជំនាញសំខាន់សម្រាប់ការអភិវឌ្ឍការចងចាំនិងការរំភើបចិត្តខាងសង្គម។ **ជ្រើសរើសពីសកម្មភាពខាងក្រោម ដើម្បីស្វែងយល់ថាតើកូនរបស់អ្នកចេះការកំណត់ចំនួនអ្វីខ្លះ។**

### សំណួរនានាដែលត្រូវសួរ៖

- ប្រើសកម្មភាពដូចខាងក្រោម ដើម្បីមើលថាតើកូនរបស់អ្នកអាចរាប់ចំនួនវត្ថុប៉ុន្មាន ដើម្បីបង្កើតសំណុំមួយឈុត។ តើកូនអាចរាប់ចំនួនវត្ថុដោយត្រឹមត្រូវបានប៉ុន្មាន?
- នៅពេលបានផ្តល់វត្ថុច្រើនជាងមួយឈុត តើកូនអាចប្រាប់អ្នកបានថា មួយណាមានច្រើនជាងឬតិចជាងឬទេ?

| | | | |
|---|---|---|---|
| **ការណែនាំគ្រួសារ៖**<br>និយាយអំពីចំនួនច្រើន តិច និងដូចគ្នា ចំពោះរបស់របរ និងភារកិច្ចប្រចាំថ្ងៃ។ លើកទឹកចិត្តកូនឱ្យនិយាយ អំពីចំនួនសរុបទាំងអស់ចំនួនច្រើនជាងមានប៉ុន្មាន និងចំនួនតិចជាងមានប៉ុន្មាន ចំពោះវត្ថុប្រើប្រាស់ប្រចាំថ្ងៃ។ | **តើអ្នកណាមានចំនួនច្រើនជាង/តិចជាង?**<br>ស្វែងរកសំណុំវត្ថុតូចមួយ ដែលអាចសមស្របនឹងដៃរបស់កូន (ថ្ម ឡេវ ដុំប្លុកតូចៗ)។ មានអ្នកម្នាក់ៗចាប់យកចំនួនមួយក្តាប់ ហើយនិយាយថាអ្នកណាមានច្រើនជាង/តិចជាង។ រាប់វត្ថុនីមួយៗពីដៃរបស់អ្នក។ កូនក៏អាចប្រើដៃទាំងពីររបស់ពួកគេផ្ទាល់ផងដែរ។ | **តើអ្នកអាចរកអ្វីនៅខាងក្រៅ?**<br>ប្រមូលវត្ថុពីខាងក្រៅដែលអាចរាប់បាន (ដុំថ្ម កំណាត់ឈើ ផ្លែសែន) ឱ្យកូនអនុវត្តរាប់វត្ថុនៅពេលពួកគេត្រូវបានផ្លាស់ទីកន្លែងមួយទៅកន្លែងមួយទៀត។ | **មនុស្ស/សត្វនៅផ្ទះរបស់អ្នក៖**<br>ប្រៀបធៀបប្រភេទមនុស្ស/សត្វនៅផ្ទះរបស់អ្នក (កូនៗ/មនុស្សពេញវ័យ មនុស្ស/សត្វ) ហើយនិយាយអំពីអ្នកណាដែលមានចំនួនច្រើនជាង និងតិចជាង ហើយមានចំនួនសរុបប៉ុន្មាន។ ឧទាហរណ៍៖ មនុស្ស 3 នាក់ និងសត្វចិញ្ចឹម 2 ក្បាល = រួមគ្នាមាន 5។ មានចំនួនមនុស្សច្រើនជាងនិងចំនួនសត្វចិញ្ចឹមតិចជាង។ |
| **ការជួយនៅជុំវិញផ្ទះ៖**<br>នៅពេលលោកអ្នកកំពុងរៀបចំតុ ឬការងារផ្ទះផ្សេងទៀត សូមឱ្យកូនជួយលោកអ្នករាប់វត្ថុ។ សួរសំណួរ ដូចជា៖ “តើយើងត្រូវការប៉ុន្មាន?” | **ក្រឡុកនិងចាក់ចេញ៖** ដាក់កាក់ 5–10 ក្នុងកែវឬប្រអប់តូចមួយ។ ឱ្យកូនក្រឡុកកែវ | **រមៀលគ្រាប់ឡុកឡាក់៖**<br>រមៀលគ្រាប់ឡុកឡាក់ពីរ។ ឱ្យកូនលោត លោតជើងមួយ ឬលោតអន្ទាក់ចំពោះចំនួនគ្រាប់ឡុកឡាក់ទាំងពីរផង នោះ។ និយាយពីចំនួនប៉ុន្មាននៅ | **បោះវត្ថុចូលកែវ៖**<br>បោះវត្ថុតូចៗដូចជាឡេវឬគ្រាប់បាល់សំឡីចូលក្នុងកែវប្លាស្ទិច។ រាប់ថាតើមានវត្ថុចំនួនប៉ុន្មានបានចូលកែវ |

| | | | |
|---|---|---|---|
| "តើយើងមានគ្រប់គ្រាន់ឬទេ?"<br>“តើយើងត្រូវការច្រើនជាងប៉ុន្មានទៀត?” | និងចាក់ចេញកាក់នោះ។<br>សួរនិងឆ្លើយសំណួរអំពីចំនួនរូបមនុស្ស/រូបភាពដែលមានលើកាក់។<br>តើមួយណាមានចំនួនច្រើនជាង?<br>ចំនួនតិចជាង?<br>តើរូបនីមួយៗមានចំនួនប៉ុន្មាន?<br>តើមានរូបសរុបទាំងអស់ប៉ុន្មាន? | លើគ្រាប់ឡុកឡាក់នីមួយៗ និងចំនួនសរុបប៉ុន្មាន។ | ហើយវត្ថុចំនួនប៉ុន្មានបានចេញក្រៅកែវ។<br>តើមានវត្ថុអ្វីបានចូលទៅក្នុងកែវឬចេញក្រៅច្រើនជាង? |